អង្គភាពក្រោមឱវាទ
Our Organization

អគ្គនាយកដ្ឋានកិច្ចការទូទៅ
General Department of Genral Affair

អគ្គនាយកដ្ឋានធនធានរ៉ែ
General Department of Mines Resource

អគ្គនាយកដ្ឋានថាមពល
General Department of Energy

អគ្គនាយកដ្ឋានប្រេងកាត
General Department of Petroleum

អាជ្ញាធរអគ្គិសនីកម្ពុជា
Electricity Authority of Cambodia

អគ្គិសនីកម្ពុជា
Electricite DU Cambodge

## អគ្គនាយកដ្ឋានធនធានរ៉ែ
General Department of Mines Resource

## លទ្ធផលការងារ / Results

### ការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ




១. សហការជាមួយ Kanazawa University សិក្សាបម្រែបម្រួល បរិស្ថានភូគព្ភសាស្ត្របឹងទន្លេសាបពី១០.០០០ឆ្នាំមកទល់បច្ចុប្បន្ន។
២. សហការជាមួយGSJសិក្សាបម្រែបម្រួលបរិស្ថានភូគព្ភសាស្ត្រ និងការវិវត្តន៍ទន្លេមេគង្គក្រោម។
៣. សិក្សាទីតាំងភូគព្ភសាស្ត្រដើម្បីអភិរក្សនៅបីទីតាំង(ភ្នំប្រុសភ្នំស្រី ភ្នំសំពៅ និងភ្នំបាក់)
៤. សិក្សាប្រភពថ្មក្រៃ និងឡាតេរីតសម្រាប់បម្រើឲ្យការអភិរក្សប្រាសាទ។
៥. សហការជាមួយ CCOPសិក្សាគ្រោះដីរអិលនៅតំបន់មួយចំនួន។
៦. សហការជាមួយ KIGAMសិក្សាការបំពុលទឹកក្រោមដីដោយអាសេនិក។
៧. សហការជាមួយ Tokyo university សិក្សាកំណាកំទេចវិទ្យានៅតំបន់កំពង់ធំ។
៨. សិក្សាផលប៉ះពាល់ដោយអាជីវកម្មមាសអនាធិបតេយ្យ។
៩. ចងក្រងសៀវភៅធនធានភូគព្ភសាស្ត្រខេត្ត-រាជធានី។

### ការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ

#### ការសិក្សាស្រាវជ្រាវធនធានរ៉ែ

មកដល់ពេលបច្ចុបន្ននេះ ក្រុមហ៊ុន ដែលបានទទួលអាជ្ញាប័ណ្ណស្វែងរុករក បាននិងកំពុងធ្វើស្វែងរុករករ៉ែ តាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ដើម្បីឈានទៅធ្វើវាយតម្លៃសក្តានុពលរ៉ែ និងធ្វើការសិក្សាសមិទ្ធិលទ្ធភាពជម្រកសេដ្ឋកិច្ចជម្រករ៉ែនោះ មុននឹងធ្វើការសំរេចថា គួរធ្វើអាជីវកម្មជម្រករ៉ែនេះដែរឬទេ ?

គិតត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានផ្តល់អាជ្ញាប័ណ្ណស្វែងរុករ៉ែជូនក្រុមហ៊ុនក្នុងស្រុក និង បរទេស(អូស្ត្រាលី ចិន វៀតណាម រុស្ស៊ី កូរ៉េ កាណាដា) ចំនួន ១០៦ ក្រុមហ៊ុន ដែលក្នុងនោះមាន ៖

- អាជ្ញាប័ណ្ណស្វែងរុករករ៉ែលោហ:ចំនួន ១៣២ អាជ្ញាប័ណ្ណ
- អាជ្ញាប័ណ្ណស្វែងរុករករ៉ែបុកស៊ីតចំនួន ២ អាជ្ញាប័ណ្ណ
- អាជ្ញាប័ណ្ណស្វែងរុករករ៉ែខ្សាច់ស ចំនួន ២ អាជ្ញាប័ណ្ណ
- អាជ្ញាប័ណ្ណស្វែងរុករករ៉ែត្បូងថ្មចំនួន ១១ អាជ្ញាប័ណ្ណ

#### ការធ្វើអាជីវកម្មធនធានរ៉ែ

មកដល់ពេលនេះ អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចេញអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែ ជូនដល់ក្រុមហ៊ុន មួយចំនួនដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធការដ្ឋាន អណ្តូងរ៉ែ រោងចក្រ និងឈានទៅធ្វើ អាជីវកម្មធនធានរ៉ែ នៅពេលខាងមុខ ៖

-អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែ(មាស) ចំនួន ០៤ អាជ្ញាប័ណ្ណ
-អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែ(ដែក) ចំនួន ០១ អាជ្ញាប័ណ្ណ
-អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ចំនួន ០១ អាជ្ញាប័ណ្ណ
-អាជ្ញាប័ណ្ណអាជីវកម្មថ្មកំបោរ សម្រាប់រោងចក្រស៊ីម៉ង់ត៍ ចំនួន ០៧ អាជ្ញាប័ណ្ណ
-អាជ្ញាប័ណ្ណអាជីវកម្មថ្មហ្វូសស្វាត ចំនួន ០១ អាជ្ញាប័ណ្ណ

រីឯគម្រោងស្នើសុំអាជីវកម្មចំនួន ០៤ ទៀតកំពុងពិនិត្យ និង ពិចារណា នៅ CDC និង ០២ គម្រោងទៀតកំពុងពិនិត្យ និងពិចារណានៅអគ្គនាយកដ្ឋានធនធានរ៉ែ មុននឹងបញ្ជូនទៅឯកឧត្តម រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល ពិនិត្យសម្រេចបញ្ជូនបន្តទៅ CDC បន្ថែម។

### ការធ្វើអាជីវកម្មរ៉ែសំណង់

មកដល់ពេលនេះ អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចេញអាជ្ញាប័ណ្ណអាជីវកម្មរ៉ែសំណង់ ជូនដល់ក្រុមហ៊ុន-អាជីវករ មួយចំនួនដើម្បីធ្វើអាជីវកម្មរ៉ែសំណង់ដូចខាងក្រោម ៖

-អាជ្ញាប័ណ្ណថ្មសំណង់ ចំនួន ១២៥ អាជ្ញាប័ណ្ណ
-អាជ្ញាប័ណ្ណខ្សាច់សំណង់ និងខ្សាច់ចាក់បំពេញ ចំនួន ១៣៥ អាជ្ញាប័ណ្ណ
-អាជ្ញាប័ណ្ណថ្មអារ-ថ្មចម្លាក់ ឡាតេរីត ចំនួន ២៤ អាជ្ញាប័ណ្ណ
-អាជ្ញាប័ណ្ណជីកអាចម៍ដី ចំនួន ២០ អាជ្ញាប័ណ្ណ

### តារាងចំណូលមិនមែនពន្ធពីការធ្វើប្រត្តិបត្តិការរ៉ែនាបណ្តាឆ្នាំកន្លងមក

| | 2010 | 2011 | 2012 | 2013 |
|---|---|---|---|---|
| ថ្លៃចុះបញ្ជីធនធានរ៉ែ | 8,700.00 | 7,500.00 | 1,100.00 | 44,520,000.00 |
| ពាក្យសុំ(កម្រែអាជ្ញាប័ណ្ណ)ធនធានរ៉ែ | 0 | 0 | 37,150.00 | 333,800,000.00 |
| ថ្លៃពន្យារបន្តអាជ្ញាប័ណ្ណធនធានរ៉ែ | 152,010.00 | 148,330.00 | 72,065.00 | 647,280,000.00 |
| ថ្លៃផ្ទេរសិទ្ធិអាជ្ញាប័ណ្ណធនធានរ៉ែ | | | 3,500.00 | 454,000,000.00 |
| **សរុប(រៀល)** | **0** | **0** | **0** | **1,479,600,000.00** |
| ឈ្នួលដីអាជីវកម្មសំភារៈសំណង់ | 316,910.39 | 418,719.96 | 379,909.30 | 635,571.89 |
| ឈ្នួលដីសិក្សាស្រាវជ្រាវ និងអាជីវកម្មរ៉ែ | 851,734.24 | 783,252.21 | 53,421.80 | 805,516.42 |
| សួយសារថ្មកំបោរ ថ្មអារ ថ្មកែវ | 124,951.23 | 183,301.64 | 1,032,612.69 | 103,198.88 |
| ពិន័យ 2% | 25,425.24 | 80,558.76 | 122,016.13 | 40,165.82 |
| សួយសារខ្សាច់នាំចេញ | 44,304.188 | 42,200.00 | 142,388.00 | 181,725 |
| សួយសារថ្មសំភារៈសំណង់ | 1,456,495.29 | 1,156,390.31 | 1,381,497.96 | 1,237,895.71 |
| សួយសារថ្មកំបោរ,ថ្មអារ និងថ្មកែវ | 0 | 0 | 0 | 103,198.88 |
| ប្រាក់តំកល់អនុវត្តកាតព្វកិច្ច និងការងារ | 0 | 0 | 1,240,000.00 | 560,000.00 |
| សរុប(ដុល្លារ) | 2,980,530.58 | 2,820,252.88 | 4,465,660.88 | 3,564,073.72 |

កាលវិភាគប្រជុំ
Meeting Schedule

Today
Displaying events after 18/3. Look for earlier events
Displaying events until 15/4. Look for more
Google Calendar

វេទិកាពិភាក្សា
Forum Discussion

បញ្ចេញមតិ
Give Comment

ឯកសារថ្មីៗ
News Document

ព្រះរាជក្រឹត្យ នស/រកត/០២១៤/១២៦
ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៨៣
ព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៨៤
ព្រះរាជក្រឹត្យ នស/រកត/០២១៤/១៤០១
ព្រះរាជក្រឹត្យ នស/រកត/០២១៤/១៤៤០



រក្សាសិទ្ធិគ្រប់យ៉ាងដោយក្រសួងរ៉ែ និងថាមពល ©២០១៤
©2014 Ministry of Mines and Energy, All Rights Reserved.